**ឯកសារសម្រាប់ការផ្សព្វផ្សាយ**

**កិច្ចប្រជុំកំពូលលើកទីពីររបស់គណៈកម្មការទន្លេមេគង្គ (MRC) និងសន្និសីទអន្តរជាតិ**
*ថ្ងៃទី 2-5 ខែ មេសា ឆ្នាំ 2014*
*សណ្ឋាគាររ៉េច ទីក្រុងហូជីមិញ វៀតណាម*

# អំពីកិច្ចប្រជុំកំពូល និងសន្និសីទអន្តរជាតិ

កិច្ចប្រជុំកំពូលលើកទីពីរ មានការចូលរួមពីនាយករដ្ឋមន្ត្រីនៃប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ពោលគឺ កម្ពុជា ឡាវ ថៃ និងវៀតណាម និងប្រតិភូមកពីប្រទេសចិន និងមីយ៉ាន់ម៉ា រួមជាមួយមេដឹកនាំផ្សេងទៀតនៅក្នុងតំបន់ អ្នកជំនាញការខាងផ្នែកធនធានទឹក និងអង្គទូតនានា ដើម្បីដោះស្រាយបញ្ហាបន្ទាន់បំផុតលើដងទន្លេមេគង្គ និងប្រភពធនធាននៃទន្លេនេះ និងកំណត់ទិសដៅយុទ្ធសាស្ត្រ និងគោលនយោបាយសម្រាប់គណៈកម្មការទន្លេមេគង្គ។

មេដឹកនាំប្រទេសនានាមានគោលដៅពង្រឹងឡើងវិញ នូវកិច្ចសហប្រតិបត្តិការឆ្លងដែន ក្នុងចំណោមប្រទេសជាសមាជិក និងជាមួយប្រទេសចិន និងមីយ៉ាន់ម៉ាផងដែរ នៅក្នុងកិច្ចប្រជុំកំពូលលើកទីពីរនេះ។ មេដឹកនាំទាំងនេះនឹងពិនិត្យមើលវឌ្ឍនភាពនៃសកម្មភាពអាទិភាពនានាដែលគណៈកម្មការទន្លេមេគង្គអនុវត្តបានបន្ទាប់ពីកិច្ចប្រជុំកំពូលលើកទីមួយដែលបានធ្វើឡើងកាលពីបួនឆ្នាំកន្លងទៅ។

នៅមុនកិច្ចប្រជុំកំពូលប្រចាំបួនឆ្នាំម្តងនេះ គណៈកម្មការទន្លេមេគង្គបានរៀបចំសន្និសីទអន្តរជាតិស្តីពីកិច្ចសហប្រតិបត្តិការខាងផ្នែកធនធានទឹក ថាមពល និងសន្តិសុខស្បៀង នៅក្នុងអាងឆ្លងដែននានា។ អ្នកជំនាញការអន្តរជាតិ និងថ្នាក់តំបន់ខាងផ្នែកធនធានទឹក អ្នកពាក់ព័ន្ធនានា និងប្រតិភូមកពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ប្រទេសចិន មីយ៉ាន់ម៉ា និងដៃគូអភិវឌ្ឍន៍ សរុបជាង 250នាក់ នឹងពិភាក្សាបញ្ហានានាដែលទាក់ទងនឹងកិច្ចប្រជុំកំពូលលើកទីពីរនេះ។ លទ្ធផលនៃសន្និសីទនេះនឹងមានរួមបញ្ចូលនៅក្នុងការពិភាក្សានៃកិច្ចប្រជុំកំពូល។

កិច្ចប្រជុំកំពូលលើកទីពីរនេះនឹងធ្វើឡើងនៅថ្ងៃទី 05 ខែ មេសា ឆ្នាំ 2014 បន្ទាប់ពីមានកិច្ចប្រជុំត្រៀមរៀបចំមួយចំនួននៅថ្ងៃទី 03-04 ខែមេសា និងសន្និសីទអន្តរជាតិនៅថ្ងៃទី 02-03 ខែមេសា។ ទីកន្លែងរៀបចំពិធីទាំងអស់នេះ គឺនៅសណ្ឋាគាររ៉េច នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម។

**ទឹក ថាមពល និងសន្តិសុខស្បៀងនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ**

តំបន់មេគង្គមិនត្រឹមតែមានកំណើននៃតម្រូវការទឹក ថាមពល និងស្បៀងអាហារប៉ុណ្ណោះទេ ប៉ុន្តែក៏កំពុងប្រឈមនឹងការប្រែប្រួលលក្ខខណ្ឌធាតុអាកាស ដែលមានឥទ្ធិពលទៅលើកសិផលនិងមានឥទ្ធិពលដទៃទៀត។

ការអភិវឌ្ឍអាងទន្លេមេគង្គកំពុងកើនឡើង ដែលរួមទាំង ការអភិវឌ្ឍថាមពលវារីអគ្គិសនីនៅលើដៃនានា និងនៅលើដងទន្លេមេ និងគម្រោងបង្វែរទឹកសម្រាប់ការស្រោចស្រពកាន់តែច្រើនជាងមុន ការធ្វើនាវាចរ និងវារីវប្បកម្មផងដែរ។ ទន្ទឹមនឹងនេះ ធនធានទឹកទន្លេមេគង្គមានតម្លៃមិនអាចកាត់ថ្លៃបាន សម្រាប់ធនធានជលផល ពោលគឺវិស័យជលផលទឹកសាបធំជាងគេលើពិភពលោក សម្រាប់ការដឹកជញ្ជូនតាមដងទន្លេ និងសម្រាប់តំបន់ដីសើម និងទំនាបលិចទឹកដែលផ្តល់របរចិញ្ចឹមជីវិតសម្រាប់ពលរដ្ឋជាច្រើនលាននាក់ ផងដែរ ជាពិសេសប្រជាជនក្រីក្រ។ និន្នាការអភិវឌ្ឍន៍នេះទទួលរងឥទ្ធិពលនៃគោលដៅអភិវឌ្ឍន៍របស់ប្រទេសតាមដងទន្លេ ក្នុងការប្រើប្រាស់ទឹក និងធនធានដែលពាក់ព័ន្ធ ដើម្បីទ្រទ្រង់គោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គមរបស់ខ្លួន និងការកាត់បន្ថយភាពក្រីក្រ។

តំបន់ទន្លេមេគង្គ ឥឡូវនេះកំពុងប្រឈមនឹងកំណើនចំនួនប្រជាជន នគរូបនីយកម្ម និងការពង្រីកឧស្សាហកម្ម កំណើនតម្រូវការថាមពល ស្បៀងអាហារ និងទឹក ព្រមទាំងការប្រែប្រួលអាកាសធាតុ និងការបាត់បង់ធនធានធម្មជាតិ។ ឧទាហរណ៍ ការអភិវឌ្ឍឆាប់រហ័សនៅក្នុងតំបន់មេគង្គ ដែលរួមមានទាំងគម្រោងថាមពលវារីអគ្គិសនីនៅលើដៃទន្លេ និងនៅលើទន្លេមេ គម្រោងបង្វែរទឹកសម្រាប់ការស្រោចស្រពច្រើនជាងមុន ការធ្វើនាវាចរ និងវារីវប្បកម្ម ជះឥទ្ធិពលមកលើការផលិតស្បៀងអាហារ និងការផ្គត់ផ្គង់ទឹក។ កំណើនកំពស់ទឹកសមុទ្រ បាននាំឲ្យមានការជ្រាបចូលទឹកប្រៃដែលបង្កការប៉ះពាល់មកលើផលិតកម្មស្បៀង។ ក្នុងពេលនេះដែរ ការធ្លាក់ភ្លៀងច្រើនមិនប្រក្រតីនៅពាក់កណ្តាលខែធ្នូកាលពីឆ្នាំទៅ បាននាំឲ្យមានការប្រែប្រួលពុំធ្លាប់មានពីមុនមកនៃកំពស់ទឹក និងជារទឹក ព្រមទាំងទឹកល្អក់ជាងមុន នៅភាគខាងត្បូងនៃប្រទេសឡាវ និងភាគខាងជើងនៃប្រទេសកម្ពុជា។

ប្រធានបទនានានៃកិច្ចប្រជុំកំពូលលើកទីពីររបស់គណៈកម្មការទន្លេមេគង្គ និងសន្និសីទអន្តរជាតិ ឆ្លុះបញ្ចាំងអំពីភាពបន្ទាន់ក្នុងការដោះស្រាយការជាប់ទាក់ទងគ្នានៃបញ្ហាទាំងនេះ។

កិច្ចប្រជុំកំពូលនេះ នឹងស្វែងរកឆន្ទៈនយោបាយរបស់មេដឹកនាំថ្នាក់ជាតិ ដើម្បីធ្វើការជាមួយគ្នាក្នុងបំណងជំនះឧបសគ្គ និងការប្រឈមនានា នៅក្នុងការអភិវឌ្ឍដោយចីរភាពនៃអាងទន្លេមេគង្គ។

អ្នកចូលរួមនៅក្នុងសន្និសីទអន្តរជាតិនេះ នឹងពិភាក្សាបញ្ហាពាក់ព័ន្ធជាអន្តរជាតិ និងនៅថ្នាក់តំបន់ ដោយផ្តោតលើការប្រឈមនានានៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

## អំពីគណៈកម្មការទន្លេមេគង្គ

គណៈកម្មការទន្លេមេគង្គ (MRC) គឺជាអង្គការអន្តររដ្ឋាភិបាលតែមួយគត់ដែលធ្វើការដោយផ្ទាល់ជាមួយរដ្ឋាភិបាលនានានៃប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាមលើផលប្រយោជន៍រួមជាក់លាក់របស់ប្រទេសទាំងនេះ ពោលគឺការគ្រប់គ្រងរួមគ្នានូវធនធានទឹករួម និងការអភិវឌ្ឍទន្លេមេគង្គដោយចីរភាព។

ក្នុងនាមជាអង្គការសម្របសម្រួល និងផ្តល់យោបល់ថ្នាក់តំបន់ ដែលដឹកនាំដោយរដ្ឋមន្ត្រីធនធានទឹក និងបរិស្ថាននៃប្រទេសទាំងបួន គណៈកម្មការទន្លេមេគង្គមានគោលដៅជានាថា ទឹកទន្លេមេគង្គត្រូវបានអភិវឌ្ឍតាមវិធីដែលមានប្រសិទ្ធភាពខ្ពស់ ដែលផ្តល់ប្រយោជន៍ដល់គ្នាទៅវិញទៅមកដល់ប្រទេសជាសមាជិកទាំងអស់ និង កាត់បន្ថយឥទ្ធិពលប្រកបដោយគ្រោះថ្នាក់មកលើប្រជាជន និងបរិស្ថាននៅក្នុងអាងទន្លេមេគង្គក្រោម។

នៅក្នុងការផ្តល់សេវាដល់ប្រទេសជាសមាជិកតាមរយៈជំនាញបច្ចេកទេស និងទស្សនវិស័យសម្រាប់អាងទន្លេមេគង្គទាំងមូល គណៈកម្មការទន្លេមេគង្គដើរតួនាទីគន្លឹះមួយនៅក្នុងការធ្វើសេចក្តីសម្រេចថ្នាក់តំបន់ និងអនុវត្តគោលនយោបាយនានាតាមវិធីមួយដែលលើកកំពស់ការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។

ចាប់តាំងពីពេលបង្កើតនៅក្នុងឆ្នាំ 1995 តាមរយៈកិច្ចព្រមព្រៀងមេគង្គ គណៈកម្មការទន្លេមេគង្គបានអនុម័តបទបញ្ញា និងនីតិវិធីមួយចំនួន ដើម្បីផ្តល់នូវដំណើរការជាលក្ខណៈប្រព័ន្ធ និងឯកភាពគ្នា សម្រាប់ការអនុវត្តកិច្ចព្រមព្រៀងនេះ។ គណៈកម្មការទន្លេមេគង្គក៏ដើរតួជាមណ្ឌលចំណេះដឹងថ្នាក់តំបន់ផងដែរសម្រាប់បញ្ហាគន្លឹះនានាមួយចំនួន ដូចជា ជលផល នាវាចរ ការគ្រប់គ្រងទឹកជំនន់ និងគ្រោះរាំងស្ងួត ការពិនិត្យតាមដានបរិស្ថាន និងការអភិវឌ្ឍថាមពលវារីអគ្គិសនី។

លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គគឺជាអង្គភាពប្រតិបត្តិ ដែលមានការិយាល័យលេខាធិការដ្ឋានចំនួនពីរនៅភ្នំពេញនៃប្រទេសកម្ពុជា និង នៅវៀងច័ន្ទ នៃប្រទេសឡាវ។ គណៈកម្មាធិការជាតិទន្លេមេគង្គគឺជាស្ថាប័នបង្គោលនៃគណៈកម្មាការនេះនៅក្នុងប្រទេសទាំងបួន និងធ្វើការសម្របសម្រួលការងារនានានៅថ្នាក់ជាតិ។

គណៈកម្មការទន្លេមេគង្គសម្របសម្រួលឲ្យអ្នកពាក់ព័ន្ធនានាជាច្រើនចូលរួមនៅក្នុងកម្មវិធីការងារ និងការកសាងផែនការយុទ្ធសាស្ត្ររបស់ខ្លួន។ ប្រទេសទាំងពីរនៅតំបន់ខាងលើនៃអាងទន្លេមេគង្គ ពោលគឺ សាធារណរដ្ឋ ប្រជាមានិតចិន និងសហភាពមីយ៉ាន់ម៉ា គឺជាដៃគូសន្ទនាជាមួយគណៈកម្មការទន្លេមេគង្គ។

គណៈកម្មការទន្លេមេគង្គបានទទួលមូលនិធិតាមរយៈវិភាគទានពីប្រទេសជាសមាជិក និងដៃគូអភិវឌ្ឍន៍ - រដ្ឋាភិបាលនៃប្រទេសនានា ធនាគារអភិវឌ្ឍន៍ និងអង្គការអន្តរជាតិ ដោយមានគោលដៅរ៉ាប់រងទាំងស្រុងខាងហិរញ្ញវត្ថុដោយប្រទេសជាសមាជិកនៅឆ្នាំ 2030។

**កម្មវិធី**

**កិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ**

**ថ្ងៃទី 2 ខែ មេសា ឆ្នាំ 2014**<u>កិច្ចប្រជុំត្រៀមរៀបចំសម្រាប់កិច្ចប្រជុំកំពូល</u>

**ថ្ងៃទី 3 ខែ មេសា ឆ្នាំ 2014**

17:00 – 19.00 **កិច្ចប្រជុំត្រៀមរៀបចំនៃគណៈកម្មាធិការរួមរបស់ MRC សម្រាប់កិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ** (កិច្ចប្រជុំបិទទ្វារ)

**ថ្ងៃទី 4 ខែមេសា ឆ្នាំ 2014**

***8.30 – 17.00 សម័យប្រជុំនៃការធ្វើសុខុដុម្មនីយកម្មដៃគូអភិវឌ្ឍន៍***

08:30 – 17.00 **កិច្ចប្រជុំត្រៀបចំនៃក្រុមប្រឹក្សាគណៈកម្មការទន្លេមេគង្គ សម្រាប់កិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ** (កិច្ចប្រជុំបិទទ្វារ)

<u>**កិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ ( MRC)**</u>

**ថ្ងៃទី 5 ខែមេសា ឆ្នាំ 2014**

09:00 - 10:00 ការចុះឈ្មោះសម្រាប់កិច្ចប្រជុំកំពូល

09:30 – 10.15 **ការជួបពិភាក្សារបស់រដ្ឋាភិបាលនៃគណៈកម្មការទន្លេមេគង្គ (កិច្ចប្រជុំបិទទ្វារ)**

10:15 - 10:30 សម្រាកពិសារកាហ្វេ

10:30 **កិច្ចប្រជុំកំពូលលើកទីពីរនៃគណៈកម្មការទន្លេមេគង្គ** *(អនុញ្ញាតឲ្យចូលរួមតែអ្នកសារព័ត៌មានដែលបានចុះឈ្មោះ)*

*ទីកន្លែង៖ បន្ទប់ Lotus Ball នៅជាន់ទីមួយ*

***10:30 - 10:45 ពិធីបើក***

10:45 - 11:00 សុន្ទរកថាបើក ដោយ **ឯកឧត្តម ង្វៀង តាន់ ហ៊្សុង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

11:00 - 11:10 សុន្ទកថាដោយ **សម្តេចអគ្គមហាសេនាបតី តេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

11:10 - 11:20 សុន្ទរថាដោយ **ឯកឧត្តម ថុងស៊ីង ថាមម៉ាវង្ស** នាយករដ្ឋមន្ត្រីនៃប្រទេសឡាវ

11:20 - 11:30 សុន្ទរកថាដោយ**ឯកឧត្តម ស៊ូរ៉ាពង្ស តូវីចាក់ចៃគុល** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស នៃព្រះរាជាណាចក្រថៃ

11:30 - 11:40 សុន្ទកថាដោយប្រតិភូនៃសាធារណរដ្ឋប្រជាមានិតចិន

11:40 - 11:50 សុន្ទរកថាដោយសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

11:50 - 12:00 សុន្ទរកថាដោយដៃគូអភិវឌ្ឍន៍

12:00 - 12:10 សេចក្តីថ្លែងការណ៍"ក្រុងហូជីមិញ" ដោយ **ឯកឧត្តម ង្វៀន តាន់ ហ៊្សុង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាម

12:10 - 12:20 ការអនុម័តលើសេចក្តីថ្លែងការណ៍ក្រុង"ហូជីមិញ"

12:20 - 12:30 ពិធីអបអរអនាគតនៃ MRC

12:30 - 12:50 ការថតរូប

13:00 - 13:30 សន្និសីទសារព័ត៌មានដោយ **ឯកឧត្តម ង្វៀន តាន់ ហ៊្សុង** នាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋសង្គមនិយមវៀតណាមនៅបន្ទប់ Sunflower Ball

13:30 ពិសាអាហារថ្ងៃត្រង់

## សាចតាអំពីកិច្ចប្រជុំកំពូលនៃគណៈកម្មការទន្លេមេគង្គ

នៅឆ្នាំ 2010 គណៈកម្មការទន្លេមេគង្គ បានរៀបចំកិច្ចប្រជុំកំពូលគណៈកម្មការទន្លេមេគង្គ ជាលើកដំបូង ដែលជាការឆ្លើយតបនឹងការកើនឡើងនៃការអភិវឌ្ឍធនធានទឹក និងធនធានដែលពាក់ព័ន្ធ នៅក្នុងអាងទន្លេមេគង្គ។ នោះជាកិច្ចប្រជុំលើកទីមួយថ្នាក់នយោបាយជាន់ខ្ពស់បំផុតនៃគណៈកម្មការទន្លេមេគង្គ។ កិច្ចប្រជុំកំពូលនោះបានធ្វើឡើងនៅថ្ងៃទី 05 ខែមេសា ដែលជាកាលបរិច្ឆេទដែលប្រទេសទាំងបួន កម្ពុជា ឡាវ ថៃ និងវៀតណាម បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមេគង្គ ឆ្នាំ 1995 និងបានក្លាយជាប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ។ កិច្ចប្រជុំកំពូលលើកទីពីរ បានធ្វើឡើងនៅកាលបរិច្ឆេទដដែលនេះ។

នៅក្នុងកិច្ចប្រជុំកំពូលលើកទីមួយនៃគណៈកម្មការទន្លេមេគង្គ ប្រមុខរដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍ទីក្រុង ហួហ៊ីន ដោយទទួលស្គាល់សមិទ្ធផលសំខាន់ៗចាប់តាំងពីឆ្នាំ 1995មក និងបានឯកភាពលើសកម្មភាពជាអាទិភាពមួយចំនួនសម្រាប់គណៈកម្មការទន្លេមេគង្គ។

វិស័យនៃសកម្មភាពជាអាទិភាពទាំងនោះគឺៈ

1. ការអនុម័ត និងអនុវត្តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដោយផ្អែកលើការគ្រប់គ្រងធនធានទឹកចម្រុះ ដែលរួមទាំងការបង្កើតប្រព័ន្ធព្យាករណ៍ និងប្រកាសព័ត៌មានជាមុននៅទូទាំងអាងទន្លេនេះទាំងមូល
2. ការសម្របសម្រួលឲ្យមានក្របខ័ណ្ឌច្បាប់អន្តរជាតិ ដែលលើកទឹកចិត្តឲ្យមានការធ្វើនាវាចរ និងពាណិជ្ជកម្មតាមដងទន្លេ
3. ការស្រាវជ្រាវ និងដោះស្រាយបញ្ហាគំរាមកំហែងចំពោះរបរចិញ្ចឹមជីវិត ដែលបង្កដោយការប្រែប្រួលអាកាសធាតុ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូថ្នាក់តំបន់ដទៃទៀត នៅក្នុងការដោះស្រាយការបំពុលដោយសារផ្សែងអ័ព្ទ
4. ការពិនិត្យតាមដាន និងចាត់វិធានការដើម្បីកែលម្អគុណភាពទឹកនៅតាមទីកន្លែងជាអាទិភាពនៃអាងទន្លេនេះ
5. ការជានានិរន្តរភាពនៃការប្រើប្រាស់ទឹកនិងធនធានពាក់ព័ន្ធដែលមានស្រាប់ និងទៅអនាគត និងជីវៈចម្រុះក្នុងទឹក តំបន់ដីសើម និងព្រៃឈើនៅក្នុងអាងទន្លេនេះ
6. ការកំណត់អត្តសញ្ញាណ និងផ្តល់យោបល់អំពីឱកាស និងការប្រឈមនានានៃថាមពលវារីអគ្គិសនី និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធដទៃទៀតនៅក្នុងអាងទន្លេនេះ ជាពិសេស ហានិភ័យនានា ដែលពាក់ព័ន្ធនឹងកិច្ចការពារសន្តិសុខស្បៀង និងរបរចិញ្ចឹមជីវិត
7. ការបន្តលើកកំពស់ការអនុវត្តនីតិវិធីសម្រាប់ការផ្លាស់ប្តូរនិងការចែករំលែកទិន្នន័យ និងព័ត៌មាន នីតិវិធីសម្រាប់ការពិនិត្យតាមដានការប្រើប្រាស់ទឹក នីតិវិធីសម្រាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង និង នីតិវិធីសម្រាប់ការរក្សាលំហូរនៅក្នុងទន្លេមេ និងការបង្ហើយនីតិវិធីសម្រាប់គុណភាពទឹក។
8. ការស្វែងយល់ និងកំណត់អត្តសញ្ញាណឱកាសសម្រាប់ពង្រីកកិច្ចសហប្រតិបត្តិការរវាងដៃគូសន្ទនាដែលមានស្រាប់របស់អង្គការនេះ និងដៃគូអភិវឌ្ឍន៍ ជាពិសេសដើម្បីដោះស្រាយការប្រឈមរួមនៃធនធានទឹក និងការប្រែប្រួលអាកាសធាតុ ក៏ដូចជា ការកំណត់អត្តសញ្ញាណដៃគូអភិវឌ្ឍន៍ថ្មីៗ និងអ្នកពាក់ព័ន្ធដទៃទៀតផងដែរ។

ចាប់តាំងពីពេលនោះមក គណៈកម្មការទន្លេមេគង្គបានអនុវត្តសេចក្តីថ្លែងការណ៍ទីក្រុងហួហ៊ីន ដើម្បីដោះស្រាយអាទិភាពនានា ដោយសម្រេចបានសមិទ្ធផលមួយចំនួន ដែលរួមមានទាំង៖

- ការអនុម័តយុទ្ធសាស្ត្រអភិវឌ្ឍន៍អាងទន្លេដែលផ្អែកលើការគ្រប់គ្រងធនធានទឹកចម្រុះដោយក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ និងការរៀបចំផែនការសកម្មភាពអាងទន្លេ ដើម្បីដោះស្រាយអាទិភាពយុទ្ធសាស្ត្រនានា ដើម្បីបង្កើនឱកាសអភិវឌ្ឍន៍ និងកាត់បន្ថយភាពមិនប្រាកដប្រជា និងហានិភ័យដែលពាក់ព័ន្ធនានា។
- ការគ្រប់គ្រងហានិភ័យទឹកជំនន់ដោយផ្តល់ការព្យាករណ៍ទឹកជំនន់ដែលផ្អែកលើកំពស់ទឹកទន្លេទទួលបាននៅស្ថានីយ៍ត្រួតពិនិត្យកំរិតទឹកចំនួន 22 តាមដងទន្លេមេនៃទន្លេមេគង្គ (ស្ថានីយ៍ចំនួន 2 ស្ថិតនៅក្នុងប្រទេសចិន)នៅក្នុងអំឡុងរដូវទឹកជំនន់(ពីថ្ងៃទី 1 ខែ មិថុនា ដល់ថ្ងៃទី 31 ខែ តុលា) និងក្នុងអំឡុងពេលលក្ខខណ្ឌធាតុអាកាសប្រកបដោយគ្រោះថ្នាក់ ផ្តល់បច្ចុប្បន្នភាពអំពីកម្រិតហានិភ័យនៃជំនន់គំហុកក្នុងអាងទន្លេមេគង្គ
- លើកកំពស់សេរីភាពនៃការធ្វើនាវាចរដោយសម្រួលឲ្យមានកិច្ចព្រមព្រៀងលើការដឹកជញ្ជូនតាមផ្លូវទឹក រវាងកម្ពុជា និងវៀតណាម ដែលបានអនុញ្ញាតឲ្យមានពាណិជ្ជកម្មឆ្លងដែន រវាងប្រទេសទាំងពីរ និងអនុញ្ញាតឲ្យនាវាបរទេសបើកបរចូលតាមប្រព័ន្ធទន្លេនេះ
- ការអនុម័តនីតិវិធីសម្រាប់គុណភាពទឹកនៅឆ្នាំ 2011 ដោយក្រុមប្រឹក្សានៃគណៈកម្មការទន្លេមេគង្គ និង ការអនុវត្តសកម្មភាពនានា ដើម្បីពិនិត្យតាមដានគុណភាពទឹក និងសុខភាពអេកូឡូស៊ី
- ដោះស្រាយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើបរចិញ្ចឹមជីវិត ដោយប្រមូលទិន្នន័យឧតុនិយម និងបង្រួមមាត្រដ្ឋាននៃការទស្សន៍ទាយអាកាសធាតុទៅអនាគត កំណត់សេណារីយ៉ូអាកាសធាតុទៅអនាគត ស្វែងយល់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើបបជលសាស្ត្រ ទឹកជំនន់ និងគ្រោះរាំងស្ងួត ប្រព័ន្ធអេកូឡូស៊ី និងជីវៈចម្រុះ និងសន្តិសុខស្បៀងនៅក្នុងតំបន់នេះ
- ការបង្កើតឧបករណ៍ និងកិច្ចផ្តួចផ្តើមនានា ដើម្បីលើកកំពស់ការយល់ដឹងអំពីថាមពលវារីអគ្គិសនីដែលមាននិរន្តរភាព ដែលរួមទាំងឧបករណ៍វាយតម្លៃនិរន្តរភាពដោយឆាប់រហ័ស (RSAT), គោលការណ៍ណែនាំបង្កើតទម្រង់ប្លង់ដំបូង និងយន្តការចែកផលក្នុងចំណោមអ្នកធ្វើគោលនយោបាយ
- ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយចិន ដែលបានឯកភាពពង្រីកអំឡុងពេលនៃការចែករម្លែកទិន្នន័យជលសាស្ត្ររយៈពេលមួយខែបន្ថែមទៀត និងបង្កើនកម្រិតញឹកញាប់នៃការផ្លោះប្តូរព័ត៌មានពីម្តង ទៅពីរដងក្នុងមួយថ្ងៃ។ ព័ត៌មាននេះ អាចជួយកែលម្អការព្យាករណ៍ទឹកជំនន់នៅក្នុងបណ្តាប្រទេសក្នុងអាងទន្លេមេគង្គក្រោម។

នៅក្នុងកិច្ចប្រជុំកំពូលលើកទីពីររបស់គណៈកម្មការទន្លេមេគង្គ ប្រមុខរដ្ឋាភិបាលនៃប្រទេសជាសមាជិកទាំងបួន នឹងពិនិត្យវឌ្ឍនភាពនៃការអនុវត្តសេចក្តីថ្លែងការណ៍ហួហ៊ីន និងវាយតម្លៃការត្រៀមរៀបចំដើម្បីអនុវត្តការប្តេជ្ញាចិត្តរបស់ប្រទេសជាសមាជិក ក្នុងការឈានទៅចក្ខុវិស័យមួយសម្រាប់គណៈកម្មការទន្លេមេគង្គ ដើម្បីមាននិរន្តរភាពហិរញ្ញវត្ថុ តាមរយៈដំណើរការនៃការធ្វើវិមជ្ឈការមុខងារស្នូលនៃការគ្រប់គ្រងអាងទន្លេ។

ប្រមុខរដ្ឋាភិបាលទាំងនេះ នឹងពិភាក្សាប្រធានបទនានាដែលទាក់ទងនឹងការអភិវឌ្ឍបច្ចុប្បន្ននៃអាងទន្លេមេគង្គ និងក្នុងការកំណត់ទិសដៅជាយុទ្ធសាស្ត្រ និងគោលនយោបាយសម្រាប់គណៈកម្មការទន្លេមេគង្គ ដើម្បីជំនះការប្រឈមទាំងនេះតាមរយៈកិច្ចសហប្រតិបត្តិការថ្នាក់តំបន់។

## ហេតុការណ៍ និងតួលេខ

- **ទន្លេមេគង្គគឺជាទន្លេធំជាងគេទីដប់លើពិភពលោក។** ទន្លេនេះជាជម្រកនៃធនធានធម្មជាតិដោយឡែក សំបូរបែប និងយ៉ាងច្រើន ដែលរួមទាំង ប្រភេទនានាដែលមានដោយកម្រ ដូចជា ត្រីរាជ ត្រីគល់រាំង និង Orcaella brevirostris, ផ្សោត។ មានរុក្ខជាតិច្រើនជាង 20.000 ប្រភេទ និងត្រីច្រើនជាង 850 ប្រភេទ នៅក្នុងអាងទន្លេមេគង្គ ដែលហូរលើផ្ទៃដីសរុបទំហំ 795.000 គ.ម$^2$ ពីទីជម្រាលភាគខាងកើតនៃខ្ពង់រាបទីបេ រហូតដល់ដែនដីសណ្តរទន្លេមេគង្គ។
- **សេដ្ឋកិច្ចនៃអាងទន្លេមេគង្គក្រោមកំពុងប្រឈមនឹងកំណើនសេដ្ឋកិច្ចឆាប់រហ័ស។** ប្រជាជន 60 លាននាក់ រស់នៅក្នុងអាងទន្លេមេគង្គក្រោម ដែលបានជួបប្រទះនឹងកំណើនយ៉ាងឆាប់រហ័សនូវចំនួនប្រជាជន។ លទ្ធផលគឺកំណើនសម្ពាធមកលើធនធានធម្មជាតិ សម្រាប់កសិកម្មស្រោចស្រព នគរូបនីយកម្ម ឧស្សាហូបនីយកម្ម ការផលិតអគ្គិសនីនិងស្បៀងអាហារ។ នៅក្នុងស្ថានភាពនៃកំណើនសេដ្ឋកិច្ចយ៉ាងរហ័សនៅទូទាំងតំបន់ និងផែនការរបស់រដ្ឋាភិបាលសម្រាប់ការតភ្ជាប់តំបន់ដ៏ធំនេះ ដើម្បីបង្កើនពាណិជ្ជកម្ម និងសេដ្ឋកិច្ច ប្រជាជនយ៉ាងច្រើននៅតែរស់នៅក្នុងលក្ខខណ្ឌនៃភាពក្រីក្រនៅឡើយ ដែលមានលទ្ធភាពតិចតួចក្នុងការទទួលបានទឹកស្អាត និងអនាម័យ ឱកាសការងារ និងជាញឹកញាប់ខ្វះស្បៀងអាហារ ឬ អគ្គិសនី។ ភាពក្រីក្រធ្ងន់ធ្ងរ មានជាក់ស្តែងនៅក្នុងតំបន់ភូមិសាស្ត្រជាច្រើន។ នៅកន្លែងដែលភាពក្រីក្រត្រូវបានកាត់បន្ថយ គម្លាតខាងសង្គម និងវិសមភាពនៅតែកើតមានជាទូទៅនៅឡើយ។
- **អន្លង់ជ្រៅៗនៅក្នុងទន្លេមេគង្គអាចមានជម្រៅរហូតដល់ 90,5ម៉ែត្រ។** អន្លង់នានាគឺជារណ្តៅដែលកើតមានដោយធម្មជាតិនៅបាតទន្លេ។ វាកើតមាននៅតាមចន្លោះក្នុងចម្ងាយប្រហាក់ប្រហែលគ្នា នៅតាមផ្នែកជាច្រើននៃដងទន្លេ និងបង្ហាញពីទម្រង់ខុសៗគ្នាជាច្រើន ដែលរួមទាំងអន្លង់រាក់ វែង នៅតាមផ្លូវទឹកធំៗដែលមានភក់ល្បាប់ និងអន្លង់អន្លង់ជ្រៅ ខ្លីនៅតាមបាតទន្លេដែលមានថ្ម។ នៅតាមដងទន្លេមេគង្គ និងដៃជាច្រើននៃទន្លេនេះ អន្លង់ជ្រៅៗផ្តល់ជាទីជម្រកយ៉ាងសំខាន់នៅរដូវប្រាំង សម្រាប់ប្រភេទត្រីសំខាន់ៗជាច្រើននៃទន្លេមេគង្គ និងជាទីជម្រកពងកូន សម្រាប់ត្រីប្រភេទខ្លះផងដែរ។ របាយអន្លង់ទាំងនេះត្រូវគេគិតថា មានឥទ្ធិពលយ៉ាងសំខាន់មកលើការវិវត្តនៃប្រព័ន្ធចំនួនបីនៃការធ្វើចរាចរ នៅតាមភូមិសាស្ត្រខុសៗគ្នាក្នុងទន្លេមគង្គ។
- **ជលផលទឹកសាបក្នុងអាងទន្លេមេគង្គក្រោម គឺជាធនធានជលផលទឹកសាបធំជាងគេតែមួយលើពិភពលោក ដែលមានទិន្នផលប្រហែល 3,9លានតោនក្នុងមួយឆ្នាំ** និងតម្លៃសរុប 3,9ពាន់លានដុល្លា។ ប្រជាជនរហូតដល់ 40លាននាក់ (ពីរភាគបីនៃប្រជាជនសរុបក្នុងអាងទន្លេមេគង្គក្រោម) មានការពាក់ព័ន្ធយ៉ាងសកម្មនៅក្នុងការនេសាទ។ ជលផលផ្តល់រវាង 50-80% នៃប្រូតេអ៊ីនពីសាច់សត្វសម្រាប់ប្រជាពលរដ្ឋនៅក្នុងអាងទន្លេមេគង្គ។ ផលចំណូលពីវិស័យនេះមានជិត 12% នៃផលទុនសរុបក្នុងស្រុករបស់ប្រទេសកម្ពុជា និងរួមចំណែក ទៅក្នុងសេដ្ឋកិច្ចរបស់ប្រទេស ច្រើនជាងផលស្រូវទៅទៀត។ នៅប្រទេសឡាវ តម្លៃផលនេសាទសមមូលនឹង 7% នៃផលទុនក្នុងស្រុកសរុបរបស់ប្រទេសនេះ។ ទោះបីមិនសូវមានសារៈសំខាន់ក៏ដោយ បើគិតជាភាគរយនៅក្នុងសេដ្ឋកិច្ចជាតិ វិស័យជលផលនៃទន្លេមេគង្គក្នុងប្រទេសថៃ និងវៀតណាមបានបន្ថែមច្រើនជាង 750លានដុល្លាអាមេរិកទៅក្នុងផលទុនក្នុងស្រុកសរុបនៃប្រទេសទាំងនេះ។
- ការបរិភោគត្រី និងសត្វក្នុងទឹកផ្សេងទៀតជាមធ្យមគឺ 45,5គ.ក្រ/ម្នាក់/ឆ្នាំ ដែលខ្ពស់ជាងតួលេខមធ្យមលើពិភពលោកដែលមានត្រឹមតែ 17,0គ.ក្រ/ម្នាក់/ឆ្នាំ។
- **តំបន់ទន្លេមេគង្គបានក្លាយជាតំបន់សកម្មបំផុតមួយនៅក្នុងពិភពលោក សម្រាប់ការអភិវឌ្ឍថាមពលវារីអគ្គិសនី។** សមត្ថភាពថាមពលវារីអគ្គិសនីច្រើនជាង 3.235MW (មេហ្គាវ៉ាត់) ត្រូវបានតម្លើង ភាគច្រើន

នៅតាមប្រព័ន្ធដៃទន្លេក្នុងអាងទន្លេមេគង្គក្រោម នៅក្នុងរយៈពេល 20ឆ្នាំកន្លងមកនេះ។ សក្តានុពលសរុបនៃថាមពលវារីអគ្គិសនីនៅតាមដងទន្លេមេគង្គគឺ 30,000 MV ដោយមានត្រឹមតែ 10% ដែលត្រូវបានអភិវឌ្ឍមកទល់បច្ចុប្បន្ននេះ។ នៅក្នុងតំបន់ជាច្រើននៃអាងទន្លេមេគង្គក្រោម ការប្រើប្រាស់អគ្គិសនីមានតិចជាង 5% នៃការប្រើប្រាស់នៅក្នុងបណ្តាប្រទេសឧស្សាហកម្មលើពិភពលោក។

គម្រោងនានាដែលនឹងផលិតថាមពល 3.209MW បន្ថែមទៀត កំពុងស្ថិតក្នុងដំណាក់កាលសាងសង់នៅតាមដៃទន្លេនានា។ គម្រោងថាមពលវារីអគ្គិសនីដែលមានសក្តានុពលចំនួន11 នៅតាមដងទន្លេមេក្នុងប្រទេសឡាវ ឡាវ-ថៃ និងកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលខុសៗគ្នានៃការសិក្សាដោយក្រុមហ៊ុនអភិវឌ្ឍន៍ឯកជន នៅក្រោមកិច្ចព្រមព្រៀងដែលបានចុះហត្ថលេខាជាមួយប្រទេសសមាជិកនៃគណៈកម្មការទន្លេមេគង្គ។ តំបន់នេះអាចសន្សំប្រមាណ 14,3ពាន់លានដុល្លា ដោយពង្រីកប្រភពថាមពលចម្រុះរបស់ខ្លួន ដែលរួមទាំង សម្រាប់ជំនួសឥន្ធនៈផូស៊ីល តាមរយៈថាមពលវារីអគ្គិសនីផងដែរ។

- **ទន្លេមេគង្គបានផ្តល់មធ្យោបាយមួយសម្រាប់ការដឹកជញ្ជូនអស់រយៈពេលជាច្រើនពាន់ឆ្នាំមកហើយ។** នៅក្នុងអាងទន្លេមេគង្គក្រោម នាវាចរតាមដងទន្លេមេគង្គ និងដៃធំៗនៃទន្លេនេះ អាចប្រព្រឹត្តទៅនៅក្នុងអំឡុងពេលនៃរដូវដែលមានកំពស់ទឹកខ្ពស់ (ប្រមាណប្រាំបីខែក្នុងមួយឆ្នាំ) លើកលែងតែប្រវែង 14គ.ម ភាគខាងជើងនៃព្រំដែនរវាងកម្ពុជា និងឡាវ ពោលគឺ ល្បាក់ទឹកធ្លាក់ខោន ដែលមិនអាចឆ្លងកាត់បាន។
- **បច្ចុប្បន្ននេះ ពាណិជ្ជកម្មក្នុងដែនទឹកសាបតាមដងទន្លេមេគង្គ នឹងបន្តកើនឡើង** ដោយមានតួលេខប៉ាន់ស្មាន 450.000តោន គិតជាទំនិញដែលត្រូវដឹកជញ្ជូនប្រចាំឆ្នាំ រវាងប្រទេសចិន និងថៃ។ នៅក្នុងដែនដីសណ្តរទន្លេមេគង្គ ទំនិញជិត ៧០% ដូចជា ស្រូវ សម្ភារៈសាងសង់ និងគ្រឿងឧបភោគបរិភោគ ត្រូវបានដឹកជញ្ជូនតាមផ្លូវទឹក។ នៅប្រទេសឡាវ នាវាតូចៗត្រូវបានដាក់ប្រតិបត្តិការដើម្បីដឹកជញ្ជូនកសិផល និងសម្ភារៈសាងសង់ទៅ និងមក តាមកន្លែងនានាដែលអាចចូលដល់តែតាមទន្លេ។ នាវាបើកបរតាមដែនទឹកសាប និងនាវាចេញទៅសមុទ្រក្រៅ ប្រតិបត្តិការចេញពីកំពង់ផែភ្នំពេញ នៅក្នុងប្រទេសកម្ពុជា ក៏ដូចជា ក្នុងដែនដីសណ្តរវៀតណាមផងដែរ។
- **កំនើនសីតុណ្ហភាព និងការធ្លាក់ភ្លៀងដែលមិនអាចព្យាករណ៍បាន កំពុងនាំមកជាមួយនូវគ្រោះរាំងស្ងួតដល់ទីកន្លែងខ្លះៗ និងការជន់លិចកន្លែងដទៃផងដែរ។** នៅទូទាំងពិភពលោក ទសវត្សចុងក្រោយនេះគឺជាអំឡុងពេលដែលមានកំណត់ត្រាអំពីការឡើងកំដៅខ្លាំងបំផុត។ ការសិក្សានានាបានព្យាករអំពីកំណើនកំពស់ទឹកភ្លៀងជាមធ្យមប្រចាំឆ្នាំ 200ម.ម។ កំនើនកំពស់ទឹកសមុទ្រកំពុងនាំមកជាមួយនូវកំណើនការជ្រាបចូលនៃទឹកប្រៃ មកលើប្រព័ន្ធអេកូឡូស៊ី និងដីដាំដំណាំដែលងាយខូចខាតនៅក្នុងដែនដីសណ្តរទន្លេមេគង្គ ដែលនេះជាមណ្ឌលផលិតកម្មអាហារចំបងមួយក្នុងតំបន់នេះ។ កំពស់ទឹកសមុទ្រលើពិភពលោកកំពុងកើនឡើងតាមអត្រាជាមធ្យម 3ម.ម ក្នុងមួយឆ្នាំ ដែលជាគំរាមកំហែងធ្វើឲ្យជន់លិចប្រមាណមួយភាគបីនៃដែនដីសណ្តរទន្លេមេគង្គ នៅក្នុងសតវត្សនេះ និងធ្វើឲ្យខូចកសិផល និងអាចធ្វើឲ្យមនុស្សជាច្រើនលាននាក់ត្រូវផ្លាស់ទីផងដែរ។
- **ថ្លៃខូចខាតជាមធ្យមប្រចាំឆ្នាំ នៃផលវិបាកពីទឹកជំនន់នៅក្នុងអាងទន្លេមេគង្គក្រោមមានពី 60 ទៅ 70 លានដុល្លាអាមេរិក** ចំណែកខ្ទង់វិជ្ជមាននៃតួលេខនេះ ផលប្រយោជន៍ជាមធ្យមនៃជំនន់ប្រចាំឆ្នាំមានប្រមាណ 8-10ពាន់លានដុល្លាអាមេរិក។ អាងទន្លេនេះងាយរងគ្រោះដោយសារផលប៉ះពាល់នៃ ការប្រែប្រួលអាកាសធាតុ ដែលរាប់បញ្ចូលការព្យាករអំពីកំណើនសីតុណ្ហភាពជាមធ្យមប្រមាណ 0,8 អង្សាសេ រហូតដល់ឆ្នាំ 2030 ក៏ដូចជាកំណើននៃកំពស់ទឹកភ្លៀងប្រចាំឆ្នាំ 200 ម.ម នៅកម្រិតតំបន់ផងដែរ។

- ប្រមាណ 60% នៃអាងទន្លេមេគង្គក្រោម គឺជាតំបន់ទំនាបត្រូពិច ជាកន្លែងដែលប្រជាជនភាគច្រើនរស់នៅ និងដែលទីជម្រកក្នុងទឹកដែលមានវិសាលភាពធំធេង និងខុសៗគ្នា ទ្រទ្រង់ដល់ត្រីជាច្រើនប្រភេទ។
- **ដោយប្រជាជនប្រមាណមួយភាគបួននៃអាងទន្លេមេគង្គក្រោមរស់ក្រោមបន្ទាត់នៃភាពក្រីក្រ តាមធម្មតាកសិកម្មគឺជាជម្រើសទីមួយសម្រាប់បង្កើនស្តង់ដារនៃការរស់នៅ** ការកែលម្អរបរចិញ្ចឹមជីវិត និងកាត់បន្ថយភាពក្រីក្រ។ នេះគឺជាប្រភពចំបងមួយនៃស្បៀងអាហារ និងប្រាក់ចំណូលសម្រាប់ប្រជាជនប្រមាណ 60% នៅក្នុងតំបន់នេះ។ កសិករនៅក្នុងអាងទន្លេមេគង្គក្រោមផលិតស្រូវគ្រប់គ្រាន់សម្រាប់ចិញ្ចឹមមនុស្ស 300លាននាក់ក្នុងមួយឆ្នាំៗ។ ទោះបីតម្រូវការស្បៀងអាហារនៅក្នុងមូលដ្ឋាននឹងកើនឡើងក៏ដោយ ជាពិសេស នៅកម្ពុជា និងឡាវ គេរំពឹងថាស្បៀងអាហារពីកសិកម្មអាចបំពេញសេចក្តីត្រូវការនៅក្នុងរយៈពេលមធ្យម។ ទោះជាយ៉ាងណាក៏ដោយ ការធានាស្បៀងសម្រាប់ទាំងអស់គ្នានឹងក្លាយជាការប្រឈមមួយនៅកម្រិតមូលដ្ឋាន ដោយសារតែទឹកជំនន់ និងភាពទន់ខ្សោយនៃបណ្តាញផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធសម្រាប់ដំណើរការក្រោយការប្រមូលផល។ ប្រទេសថៃទំនងជាបន្តនៅជាអ្នកនាំចេញស្រូវចំបងមួយ ប៉ុន្តែវៀតណាមទំនងជាត្រូវការផលិតផលដែលដែលលើសពីការនាំចេញបច្ចុប្បន្នរបស់ខ្លួនសម្រាប់ការប្រើប្រាស់ក្នុងស្រុក។
- នៅក្នុងអាងទន្លេមេគង្គក្រោម មានទីតាំងស្រោចស្រពច្រើនជាង 12.500កន្លែង។ តិចជាង 10% នៃផ្ទៃដីកសិកម្មសរុបបានទទួលការស្រោចស្រពនៅរដូវប្រាំង។ **ការធ្វើពិពិធកម្មដំណាំ គឺជាយុទ្ធសាស្ត្របង្កើនផលិតផលកសិកម្មប្រកបដោយសក្តានុពល។** ដោយសារដំណាំដែលមានតម្លៃខ្ពស់ជាច្រើនត្រូវការទឹកតិចជាងស្រូវ ការដាំដំណាំផ្សេងទៀតអាចបង្កើនផលិតភាពនៃទឹក។ ការធ្វើបែបនេះក៏អាចជួយទប់ទល់នឹងតម្រូវការស្បៀងអាហារកាន់តែច្រើនឡើង និងការពង្រីកប្រភពប្រាក់ចំណូលរបស់កសិករផងដែរ។ វាលស្រែផលិតស្បៀងអាហារ ប៉ុន្តែវាក៏ផ្តល់មុខងារផ្សេងទៀតដែលមានប្រយោជន៍ផងដែរ ដែលរួមទាំង កាត់បន្ថយទឹកជំនន់ ការបំពេញដង្ហើមទឹកក្រោមដីឡើងវិញ ការធ្វើឲ្យមានស្ថិរភាពជារទឹកទន្លេ ការចាប់យកនិងប្រើប្រាស់ទឹកឡើងវិញសម្រាប់ការស្រោចស្រព ការត្រួតពិនិត្យការហូរច្រោះ និងនិយ័តកម្មមីក្រូអាកាសធាតុ។ ការធ្វើពិពិធកម្មក៏អាចរាប់បញ្ចូល ការរួមផ្សំរវាងកសិកម្ម និងជលផលផងដែរ និងការធ្វើសមាហរណកម្មសត្វចិញ្ចឹមជាបន្ថែមផងដែរ។
- ទោះបីជាមានកង្វល់ដែលបានលើកឡើងនៅដើមឆ្នាំ 2014 ដោយប្រជាជនដែលរស់ក្នុងសហគមន៍តាមដងទន្លេតាមព្រំប្រទល់រវាងប្រទេសថៃ និងឡាវអំពីការប្រែប្រួលមិនប្រក្រតីនៃកម្រិតកំពស់ទឹកក្នុងទន្លេមេគង្គក៏ដោយ ដែលរួមទាំងអ្វីដែលពួកគេចាត់ទុកថាជាកម្រិតកំពស់ទាបជាងធម្មតា **ទិន្នន័យរបស់គណៈកម្មការទន្លេមេគង្គបង្ហាញថា កម្រិតកំពស់ទឹកនៅតាមផ្នែកជាច្រើននៃដងទន្លេមេគង្គនៅតែខ្ពស់ជាងតួលេខមធ្យមរយៈពេលវែង ចាប់តាំងពីខែវិច្ឆិកា ឆ្នាំ 2013 ដល់ដើមខែមីនា ឆ្នាំ 2014។** ការការប្រែប្រួលមិនប្រក្រតី ត្រូវបានសង្កេតឃើញនៅខែធ្នូ និងខែកុម្ភៈកន្លងមកនេះ។

  ឧទាហរណ៍ ការឡើងខ្ពស់ភ្លាមៗនៃជារទឹកនៅពាក់កណ្តាលខែធ្នូ ឆ្នាំ 2013 បានធ្វើឲ្យកំពស់ទឹកខ្ពស់ជាងកម្រិតខ្ពស់បំផុតដែលបានកត់ត្រាកន្លងមកសម្រាប់អំឡុងពេលដូចគ្នាក្នុងឆ្នាំកន្លងទៅ។ ចំណុចនេះត្រូវគេជឿថាបានបង្កដោយការធ្លាក់ភ្លៀងមិនប្រក្រតីជាច្រើននៅភាគខាងត្បូងនៃប្រទេសចិន និងភាគខាងជើងប្រទេសឡាវ។ នៅដើមខែកុម្ភៈឆ្នាំ 2014 កម្រិតកំពស់ទឹកនៅឈៀងសែននៅប្រទេសថៃបានធ្លាក់ចុះឆាប់រហ័សអស់ 1ម ប៉ុន្តែកម្រិតកំពស់ដែលធ្លាក់ចុះនេះនៅតែខ្ពស់ជាងយ៉ាងច្រើនបើធៀបនឹងតួលេខមធ្យមរយៈពេលវែង។ បន្ទាប់មកកម្រិតកំពស់ទឹកវិលត្រឡប់មកកម្រិតខ្ពស់វិញយ៉ាងឆាប់រហ័ស។ ការប្រែប្រួលឆាប់រហ័សនេះទំនងជាបានទទួលឥទ្ធិពលពីសកម្មភាពរបស់មនុស្ស (ដោយសារគ្មានការពាក់ព័ន្ធជាមួយការធ្លាក់ភ្លៀងឡើយ)។

# មណ្ឌលព័ត៌មាន និងឱកាសសម្រាប់ការទទួលព័ត៌មាន

## មណ្ឌលព័ត៌មាន

មណ្ឌលព័ត៌មានស្ថិតនៅក្នុងបន្ទប់ Camellia នៅជាន់ទី 2 នៃសណ្ឋាគាររ៉េច និងចាប់ប្រតិបត្តិការពីថ្ងៃទី 2-5 ខែមករា។ បន្ទប់នេះមានប្រព័ន្ធភ្ជាប់អ៊ិនធឺណិតដោយឥតខ្សែ និងកន្លែងរួមមួយសម្រាប់ប្រើការ។ ការសម្ភាសក៏អាចធ្វើនៅទីនេះបានផងដែរ។

ការប្រើប្រាស់មណ្ឌលព័ត៌មាននេះអាចអនុញ្ញាតឲ្យសម្រាប់តែអ្នកសារព័ត៌មានដែលបានចុះឈ្មោះ។ នៅគ្រប់ពេលទាំងអស់ អ្នកសារព័ត៌មានត្រូវបានស្នើឲ្យពាក់ស្លាកអ្នកសារព័ត៌មាន ដែលកំណត់ដោយសន្និសីទសារព័ត៌មាន និងកិច្ចប្រជុំកំពូលនេះ។

អ្នកសារព័ត៌មានដែលបានចុះឈ្មោះ អាចមកទទួលយកស្លាកឈ្មោះរបស់ខ្លួននៅបន្ទប់ Camellia នៅជាន់ទី 2។

## ឱកាសសម្រាប់អ្នកសារព័ត៌មាន

- **វគ្គថតរូបរួមគ្នា** នៅម៉ោង 12.30 នៃថ្ងៃទី 5 ខែ មេសា នៅបន្ទប់ Lotus Ball
- **សន្និសីទសារព័ត៌មាន**នៅម៉ោង 13.00 ថ្ងៃទី 5 ខែមេសា ដោយនាយករដ្ឋមន្ត្រីវៀតណាម នៅបន្ទប់ Sunflower Ball
- **សេចក្តីប្រកាសព័ត៌មាន**របស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ស្តីពីលទ្ធផលនៃកិច្ចប្រជុំកំពូលលើកទីពីរ នឹងធ្វើឡើងនៅថ្ងៃទី 5 ខែ មេសា
- **សេចក្តីប្រកាសព័ត៌មាន**របស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ ស្តីពីលទ្ធផលនៃសន្និសីទអន្តរជាតិនឹងធ្វើឡើងនៅថ្ងៃទី 3 ខែ មេសា នៅពេលបញ្ចប់សន្និសីទនេះ
- **ការសុំសម្ភាស**ជាមួយប្រតិភូមកពីប្រទេសជាសមាជិកគណៈកម្មការទន្លេមេគង្គ ចិន មីយ៉ាន់ម៉ា និងដៃគូអភិវឌ្ឍន៍ ដោយត្រូវស្នើសុំជាមុន
- **រូបថតដែលមានកម្រិតច្បាស់**អំពីពិធីនានានឹងមានសម្រាប់អ្នកសារព័ត៌មានប្រើប្រាស់នៅលើវេបសាយអំពីកិច្ចប្រជុំកំពូលនេះ ក្នុងផ្នែកមណ្ឌលព័ត៌មាន ដោយមានការទទួលស្គាល់ម្ចាស់ប្រភព ពោលគឺគណៈកម្មការទន្លេមេគង្គ ។
- **សេចក្តីថ្លែងការណ៍នឹងមានផ្តល់ជូននៅនឹងកន្លែងក្នុងមណ្ឌលព័ត៌មាន។**

## ការប្រើប្រាស់ព័ត៌មាន

អ្នកសារព័ត៌មានដែលបានចុះឈ្មោះអាចចូលរួមនៅក្នុងគ្រប់វគ្គទាំងអស់នៃសន្និសីទអន្តរជាតិ និងវគ្គពេញអង្គនៃកិច្ចប្រជុំកំពូលរបស់គណៈកម្មការទន្លេមេគង្គ។ សូមបញ្ជាក់ថា មិនអនុញ្ញាតឲ្យអ្នកសារព័ត៌មានចូលរួមនៅក្នុងការប្រជុំត្រៀមរៀបចំរបស់គណៈកម្មការទន្លេមេគង្គ សម័យប្រជុំសុខុដុម្មនីយកម្មដៃគូអភិវឌ្ឍន៍ និងការជួបពិភាក្សានៃរដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំកំពូលនេះឡើយ។

ចំពោះព័ត៌មានបន្ថែម សូមអាននៅក្នុង៖ http://www.mrcsummit.org/

# ប្លង់បន្ទប់ក្នុងសណ្ឋាគាររ៉េច

ជាន់ទី 1




ជាន់ទី 2

